**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៧ ២៧៧នាក់ នៃរោងចក្រ សហគ្រាស ទាំង៧ នៃវិស័យកាត់ដេរ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលត្រូវបានការព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី១នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្រោយការបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញទន់ ក្នុងនោះចំនួន៖

- ១៥៣ ៩០០រៀល (៣៨ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ៥៤ថ្ងៃ
- ៣០៧ ៨០០រៀល (៧៦ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៥១ថ្ងៃ ឡើងទៅ។

ក្រសួងសូមរំឮកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៧ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៤ កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ
## ចំនួន ៧ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 1 | ក្រុមហ៊ុន អេហ្វ ដាបប៊ែលយូ ខេ ខេ (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ម៉ាស្ទេច អ៊ីនខេម (ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ហ្វផូណា អ៊ិនធើណេសិនណល (ខេមបូឌា) អ៊ិនដាសស្ទ្រី ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ជីនីនស្ស៊ីឡឺ អឺកែវីល អ៊ីនធើណេសិនណល លីមីតធីត | កំពង់ស្ពឺ |
| 5 | ក្រុមហ៊ុន ម៉ាស្ទ័រ-យើង ហ្គាម៉ិន មេនូហ្វេកធឺរីង (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 6 | ក្រុមហ៊ុន ស៊ូកៀល (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុន វេនធូរ៉ា លេដឺវែរ អឹមអែហ្វវ៉ាយ (ស៊ីឌី) ឯ.ក | កំពង់ស្ពឺ |